តេលេក្រាម ឯកសារមន្ត្រីសាធារណៈ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៤៨ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការអនុវត្តកម្មវិធីជាតិគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្រ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២២១ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ៥៦ អនក្រ. បក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការបង្កើតមូលនិធិហិរញ្ញប្បទានគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ៦៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ ស្តីពីការបង្កើតមូលនិធិជាតិជំនួយសង្គម ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ២៣៤ អនក្រ. បក ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ៣២៩ អនក្រ.បក ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការអនុវត្តកម្មវិធីជាតិជំនួយសង្គមផ្នែកបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស សម្រាប់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ កំណត់អំពីវិធាន នីតិវិធី លក្ខខណ្ឌ យន្តការគ្រប់គ្រង និងការផ្តល់អត្ថប្រយោជន៍នៃកម្មវិធីជាតិគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្រ ដែលហៅកាត់ថា **"កម្មវិធី"** ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ពលរដ្ឋក្រីក្រ ពន្លឿនការចាកចេញពីភាពក្រីក្រ ប្រកបដោយចីរភាព និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន។

**មាត្រា២.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះគ្រួសារក្រីក្រដែលមានបណ្ណសមធម៌ នៅតាមទីតាំងភូមិសាស្ត្រក្នុងរាជធានី ខេត្តគោលដៅដែលត្រូវបានជ្រើសរើសសម្រាប់ការអនុវត្តកម្មវិធី។

## ជំពូកទី២
## គោលការណ៍ និងយន្តការគ្រប់គ្រងកម្មវិធី

**មាត្រា៣.-**

កម្មវិធីជាតិគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្រ ជួយកសាងសមត្ថភាព ភាពធន់ និងលើកកម្ពស់ជីវភាពរបស់គ្រួសារក្រីក្រ ដោយត្រូវអនុវត្ត និងប្រកាន់ខ្ជាប់នូវគោលការណ៍ពង្រីក

វិសាលភាពជាជំហាន ដោយផ្អែកលើចីរភាពហិរញ្ញវត្ថុ និងការបំពេញឱ្យគ្នាជាមួយនឹងកម្មវិធីគាំពារសង្គម ដែលមានស្រាប់នានា ដើម្បីធានាឱ្យបានប្រសិទ្ធភាព និងសក្តិសិទ្ធិភាព។

**មាត្រា៤.-**

កម្មវិធីជាតិគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្រ ត្រូវដឹកនាំ និងផ្តល់ការតម្រង់ទិស គោលនយោបាយដោយក្រុមប្រឹក្សាជាតិគាំពារសង្គម ដែលមានអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម (អ.ក.គ.) ជាសេនាធិការ ទទួលបន្ទុកសម្របសម្រួលការអនុវត្តកម្មវិធី កំណត់ទីតាំងភូមិសាស្ត្រគោលដៅសម្រាប់ការអនុវត្តកម្មវិធី ធានាហិរញ្ញប្បទានថវិកា និងតាមដាន និងវាយតម្លៃ លើការអនុវត្តកម្មវិធី ដោយមានមូលនិធិជាតិជំនួយសង្គម (ម.ជ.ជ.) ជាប្រតិបត្តិករទទួលបន្ទុកបើកផ្តល់សាច់ប្រាក់ឧបត្ថម្ភ និងមានរដ្ឋបាលរាជធានី ខេត្តគោលដៅ ជាប្រតិបត្តិករទទួលបន្ទុកដឹកនាំការអនុវត្តកម្មវិធីនៅថ្នាក់ក្រោមជាតិ។

ក្រុមប្រឹក្សាជាតិគាំពារសង្គម អាចបង្កើតយន្តការអន្តរក្រសួង ស្ថាប័ន ដើម្បីសម្របសម្រួល និងអនុវត្តកម្មវិធី តាមការចាំបាច់។

**មាត្រា៥.-**

មូលនិធិជាតិជំនួយសង្គម ជាប្រតិបត្តិករដឹកនាំ និងគ្រប់គ្រងការបើកផ្តល់សាច់ប្រាក់ឧបត្ថម្ភសម្រាប់កម្មវិធីជាតិគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្រ។

ម.ជ.ជ. ទទួលខុសត្រូវក្នុងការបើកផ្តល់ប្រាក់ឧបត្ថម្ភដល់គ្រួសារទទួលផល និងចូលរួមតាមដានការប្រើប្រាស់សាច់ប្រាក់ឧបត្ថម្ភ និងដោះស្រាយបញ្ហានានា នៅក្នុងដំណាក់កាលនៃការបើកផ្តល់សាច់ប្រាក់ឧបត្ថម្ភ។

**មាត្រា៦.-**

ម.ជ.ជ. ត្រូវរៀបចំសៀវភៅប្រតិបត្តិគោលស្តីពីការបើកផ្តល់សាច់ប្រាក់ឧបត្ថម្ភសម្រាប់កម្មវិធី ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការបើកផ្តល់សាច់ប្រាក់ឧបត្ថម្ភ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

**មាត្រា៧.-**

រដ្ឋបាលរាជធានី ខេត្តគោលដៅ ជាប្រតិបត្តិករបច្ចេកទេសទទួលបន្ទុកដឹកនាំការអនុវត្តកម្មវិធីនៅថ្នាក់ក្រោមជាតិក្នុងដែនសមត្ថកិច្ចរបស់ខ្លួន រួមទាំងការចុះឈ្មោះចូលក្នុងកម្មវិធី ការផ្តល់ការបណ្តុះបណ្តាល ការចុះបង្វឹកតាមខ្នងផ្ទះ ការបញ្ជាក់លក្ខខណ្ឌចូលរួមរបស់អ្នកទទួលផលក្នុងការបណ្តុះបណ្តាលនិងការបង្វឹក ការតាមដានការប្រើប្រាស់សាច់ប្រាក់ឧបត្ថម្ភ និងការតាមដាន ត្រួតពិនិត្យ និងដោះស្រាយបញ្ហាប្រឈមនានាក្នុងការអនុវត្តកម្មវិធី។

រដ្ឋបាលរាជធានី ខេត្ត ត្រូវផ្តល់ទិន្នន័យគ្រួសារក្រីក្រដែលត្រូវបានជ្រើសរើសក្នុងភូមិសាស្ត្រគោលដៅជូន ម.ជ.ជ. ដើម្បីបញ្ជាក់ការចុះឈ្មោះចូលក្នុងកម្មវិធី។

**មាត្រា៨.-**

រដ្ឋបាលរាជធានី ខេត្តគោលដៅ ត្រូវរៀបចំយន្តការដឹកនាំ និងគ្រប់គ្រងការអនុវត្តកម្មវិធីនៅថ្នាក់ក្រោមជាតិក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយមានសមាសភាពចូលរួមពីគ្រប់មន្ទីរពាក់ព័ន្ធ និងដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តនានា និងសៀវភៅប្រតិបត្តិគោលស្តីពីការអនុវត្តកម្មវិធីនៅថ្នាក់ក្រោមជាតិក្នុងក្របខណ្ឌរដ្ឋបាលរាជធានី ខេត្តរបស់ខ្លួន។



ᡃ

## ជំពូកទី៣
## លក្ខខណ្ឌនៃការទទួលផល និងអត្ថប្រយោជន៍

**មាត្រា៩.-**

លក្ខណៈវិនិច្ឆ័យ ក្នុងការកំណត់ទីតាំងភូមិសាស្ត្រគោលដៅសម្រាប់ការអនុវត្តកម្មវិធី មានដូចខាងក្រោម៖

- អត្រាភាពក្រីក្រខ្ពស់
- អត្រាសន្តិសុខស្បៀងទាប និង
- ហានិភ័យខ្ពស់ពីការប្រែប្រួលអាកាសធាតុ។

ការអនុវត្តកម្មវិធីក្នុងទីតាំងភូមិសាស្ត្រគោលដៅនីមួយៗដែលត្រូវបានជ្រើសរើស មានរយៈពេលសរុបចំនួន ២៤ ខែ ប៉ុណ្ណោះ។

ចំនួនគ្រួសារគោលដៅ និងទីតាំងភូមិសាស្ត្រជាក់លាក់ ស្របតាមលក្ខណៈវិនិច្ឆ័យខាងលើ សម្រាប់ការពង្រីកវិសាលភាពនៃកម្មវិធី ត្រូវកំណត់ជារៀងរាល់ឆ្នាំ ដោយសេចក្តីសម្រេចរបស់ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម ផ្អែកតាមភាពទ្រទ្រង់បាននៃថវិកាជាតិ។

**មាត្រា១០.-**

គ្រួសារគោលដៅដែលកំពុងរស់នៅក្នុងទីតាំងភូមិសាស្ត្រគោលដៅដែលត្រូវបានជ្រើសរើសអនុវត្តកម្មវិធី ត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម៖

- ត្រូវមានបណ្ណសមធម៌ ក្រ១ ឬក្រ២ ដែលមានសុពលភាព និង
- ត្រូវមានសមាជិកគ្រួសារយ៉ាងតិចមួយរូបដែលមានអាយុចាប់ពី ១៥ឆ្នាំ ដល់៦៥ឆ្នាំ ដែលអាចមានលទ្ធភាពពលកម្មដើម្បីចូលរួមនៅក្នុងកម្មវិធី។

គ្រួសារទទួលផលដែលបានចុះឈ្មោះចូលរួមក្នុងកម្មវិធីត្រូវធានាឱ្យបាននូវការចូលរួមយ៉ាងសកម្ម និងពេញលេញ។ គ្រួសារទទួលផលដែលមានសមាជិកមានលទ្ធភាពពលកម្មតែមួយរូប មិនអាចទទួលបានអត្ថប្រយោជន៍ពីកម្មវិធីជាតិជំនួយសង្គមផ្នែកបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស សម្រាប់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ ក្នុងពេលដំណាលគ្នានោះទេ។

លក្ខខណ្ឌលម្អិតសម្រាប់ចូលរួមកម្មវិធី ត្រូវកំណត់ក្នុងសៀវភៅប្រតិបត្តិគោលស្តីពីការអនុវត្តកម្មវិធីរបស់ ម.ជ.ជ. និងរដ្ឋបាលរាជធានី ខេត្តគោលដៅ។

**មាត្រា១១.-**

គ្រួសារគោលដៅដែលបានចុះឈ្មោះចូលក្នុងកម្មវិធី ត្រូវទទួលបានអត្ថប្រយោជន៍ ដូចខាងក្រោម៖

- ការបណ្តុះបណ្តាល និងការបង្វឹកអំពីការបង្កើតមុខរបរ និងបំណិនជីវិត
- ការចុះសួរសុខទុក្ខ និងការបង្វឹកតាមខ្នងផ្ទះជាប្រចាំ
- ការផ្តល់សាច់ប្រាក់ឧបត្ថម្ភសម្រាប់ការចូលរួមការបណ្តុះបណ្តាលផ្សារភ្ជាប់ជាមួយលក្ខខណ្ឌវត្តមាន និង
- ការផ្តល់ប្រាក់ដើមទុនសម្រាប់ទ្រព្យសកម្ម។

**មាត្រា១២.-**

គ្រួសារទទួលផលនៃកម្មវិធី ត្រូវទទួលបានការឧបត្ថម្ភសាច់ប្រាក់ ដូចខាងក្រោម៖

| ល.រ. | អត្ថប្រយោជន៍ | ចំនួនប្រាក់ឧបត្ថម្ភ |
|---|---|---|
| ១ | ការឧបត្ថម្ភសម្រាប់ការចូលរួមការបណ្តុះបណ្តាល ៧ ដង | ៤០ ០០០ រៀល ក្នុង១ ដង |
| ២ | ការឧបត្ថម្ភប្រាក់ដើមទុនសម្រាប់ទ្រព្យសកម្ម ១ លើក | ៩៦០ ០០០ រៀល |



9

ការឧបត្ថម្ភសាច់ប្រាក់មិនត្រូវលើស ១ ២៤០ ០០០ (មួយលានពីររយសែសិបពាន់) រៀល ក្នុងមួយវដ្តនៃកម្មវិធី។

នីតិវិធីនៃការចុះឈ្មោះចូលកម្មវិធី ការធ្វើបច្ចុប្បន្នកម្មវត្តមាន កាលបរិច្ឆេទបើកផ្តល់សាច់ប្រាក់ ព្រមទាំងដំណើរការកម្មវិធីលម្អិត ត្រូវកំណត់ក្នុងសៀវភៅប្រតិបត្តិគោលស្តីពីការបើកផ្តល់សាច់ប្រាក់ឧបត្ថម្ភសម្រាប់កម្មវិធី។

## ជំពូកទី៤

## តួនាទី និងភារកិច្ចរបស់ក្រសួង ស្ថាប័នដឹកនាំ ក្នុងការអនុវត្តកម្មវិធី

**មាត្រា១៣.-**

ក្រុមប្រឹក្សាជាតិគាំពារសង្គម ដោយមានអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម (អ.ក.គ.) ជាសេនាធិការ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- សម្របសម្រួលកិច្ចសហការរវាងក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធក្នុងការអនុវត្តកម្មវិធី
- ផ្តល់ការតម្រង់ទិសផ្នែកគោលនយោបាយ យុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្ត ក្នុងការអនុវត្តកម្មវិធី
- ពិនិត្យ និងសម្រេចលើផែនការពង្រីកវិសាលភាពប្រចាំឆ្នាំ
- ធានាឱ្យបានវិហូរថវិកាសម្រាប់អនុវត្តកម្មវិធីប្រកបដោយប្រសិទ្ធភាព
- កំណត់កាលបរិច្ឆេទនៃការដាក់ឱ្យអនុវត្តកម្មវិធី
- ពិនិត្យ តាមដាន វាយតម្លៃ និងផ្តល់យោបល់លើវឌ្ឍនភាពនៃការអនុវត្តកម្មវិធី
- ដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី
- ទទួលដោះស្រាយវិវាទ ឬបណ្តឹងដែលមិនអាចដោះស្រាយបាននៅកម្រិតប្រតិបត្តិករ និង
- រៀបចំរបាយការណ៍វឌ្ឍនភាព នៃការអនុវត្តកម្មវិធី ជូនរាជរដ្ឋាភិបាល។

**មាត្រា១៤.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ពិនិត្យ ផ្តល់យោបល់ និងសម្រេចលើគម្រោងថវិកាសម្រាប់អនុវត្តកម្មវិធី
- វិភាជថវិកាសម្រាប់ការអនុវត្តកម្មវិធី
- ពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍អនុវត្តថវិកា និងសមិទ្ធកម្មរបស់កម្មវិធី និង
- សហការក្នុងការតាមដាន វាយតម្លៃ និងគាំទ្រការដោះស្រាយបញ្ហាប្រឈមដែលពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីទៅតាមសមត្ថកិច្ចរៀងខ្លួន។

**មាត្រា១៥.-**

ក្រសួងផែនការ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- អនុវត្តការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រតាមការស្នើសុំ និងធ្វើបច្ចុប្បន្នកម្មទិន្នន័យជាប្រចាំ
- ផ្តល់ទិន្នន័យគ្រួសារក្រីក្រ សម្រាប់ការអនុវត្តកម្មវិធី តាមរយៈសន្ធានកម្ម នៃកម្មវិធីកុំព្យូទ័រ (API) និង
- សហការក្នុងការតាមដាន វាយតម្លៃ និងគាំទ្រការដោះស្រាយបញ្ហាប្រឈមដែលពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីទៅតាមសមត្ថកិច្ចរៀងខ្លួន។



៥

**មាត្រា១៦.-**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- កំណត់យុទ្ធសាស្ត្រសម្រាប់ការអនុវត្តកម្មវិធី
- តាមដាន និងវាយតម្លៃលទ្ធផលនៃការអនុវត្តផ្នែកបច្ចេកទេស
- ណែនាំវិធានការដោះស្រាយពាក់ព័ន្ធនឹងការអនុវត្តផ្នែកបច្ចេកទេស
- ពិនិត្យ ផ្តល់យោបល់ និងសម្រេចលើផែនការអភិវឌ្ឍន៍ ផែនការថវិកា របាយការណ៍ហិរញ្ញវត្ថុ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត
- សហការ និងផ្តល់ការគាំទ្រដល់ការអនុវត្តកម្មវិធីតាមការចំបាច់។

**មាត្រា១៧.-**

ក្រសួងមហាផ្ទៃ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- សហការពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់ការអនុវត្តកម្មវិធី
- សហការពង្រឹងការអនុវត្តតួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីអនុវត្តកម្មវិធី
- រៀបចំ និងពិនិត្យកែសម្រួលលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ តាមការចាំបាច់ ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការអនុវត្តតួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តកម្មវិធី និង
- សហការក្នុងការតាមដាន វាយតម្លៃ និងគាំទ្រការដោះស្រាយបញ្ហាប្រឈមដែលពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា១៨.-**

ក្រសួងកិច្ចការនារី មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- សហការជាមួយក្រសួង ស្ថាប័នក្នុងការអនុវត្តកម្មវិធីឱ្យឆ្លើយតបនឹងយេនឌ័រ
- ផ្តល់ការគាំទ្រដល់មន្ទីរកិច្ចការនារី និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តកម្មវិធីពាក់ព័ន្ធនឹងយេនឌ័រ
- សហការក្នុងការតាមដាន វាយតម្លៃ និងគាំទ្រការដោះស្រាយបញ្ហាប្រឈមដែលពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីទៅតាមសមត្ថកិច្ចរៀងខ្លួន។

**មាត្រា១៩.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ធានាឱ្យមានមន្ត្រីកសិកម្មដែលមានបទពិសោធនៅតាមទីតាំងគោលដៅនៃកម្មវិធី ដើម្បីគាំទ្រការអនុវត្ត
- ផ្តល់ការគាំទ្រ និងរៀបចំសហគមន៍កសិកម្មនៅទីតាំងគោលដៅនៃកម្មវិធី និង
- សហការក្នុងការតាមដាន វាយតម្លៃ និងគាំទ្រការដោះស្រាយបញ្ហាប្រឈមដែលពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីទៅតាមសមត្ថកិច្ចរៀងខ្លួន។

**មាត្រា២០.-**

ក្រសួង-ស្ថាប័នពាក់ព័ន្ធ រួមមានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងធម្មការ និងសាសនា ព្រមទាំងមន្ទីរ អង្គភាពជំនាញ ត្រូវចូលរួមគាំទ្រការអនុវត្តកម្មវិធីនេះ តាមតួនាទី និងភារកិច្ចរៀងៗខ្លួន។

**មាត្រា២១.-**

មូលនិធិជាតិជំនួយសង្គម មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ដឹកនាំ និងគ្រប់គ្រងការបើកផ្តល់សាច់ប្រាក់ជូនគ្រួសារទទួលផល ដោយសហការជាមួយភ្នាក់ងារបើកផ្តល់



9

- រៀបចំឯកសារគតិយុត្ត និងឯកសារពាក់ព័ន្ធតាមការចាំបាច់ សម្រាប់គ្រប់គ្រង និងចាត់ចែងការបើកផ្តល់សាច់ប្រាក់ឱ្យមានប្រសិទ្ធភាព
- រៀបចំប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មានសម្រាប់ការបើកផ្តល់សាច់ប្រាក់ឧបត្ថម្ភ
- ផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងអំពីកម្មវិធីដល់គ្រួសារគោលដៅនៅតាមទីតាំងភូមិសាស្ត្រគោលដៅ និងដល់ភាគីពាក់ព័ន្ធ
- សហការ និងសម្របសម្រួលជាមួយរដ្ឋបាលរាជធានី ខេត្តគោលដៅ និងភាគីពាក់ព័ន្ធដើម្បីអនុវត្តកម្មវិធីឱ្យបានរលូន
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំសម្រាប់ការបើកផ្តល់សាច់ប្រាក់ឧបត្ថម្ភ និងដំណើរការកម្មវិធី
- តាមដានវឌ្ឍនភាពនៃការប្រើប្រាស់សាច់ប្រាក់ឧបត្ថម្ភរបស់គ្រួសារទទួលផល ព្រមទាំងដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការបើកផ្តល់សាច់ប្រាក់ឧបត្ថម្ភ និង
- រាយការណ៍ជាប្រចាំជូន អ.ក.គ. និងស្ថាប័នពាក់ព័ន្ធ អំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តកម្មវិធី។

**មាត្រា២២.-**

រដ្ឋបាលរាជធានី ខេត្តគោលដៅ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ដឹកនាំ និងគ្រប់គ្រងការអនុវត្តកម្មវិធីជារួមនៅរដ្ឋបាលរាជធានី ខេត្តសាមី
- រៀបចំលិខិតបទដ្ឋាន និងឯកសារពាក់ព័ន្ធ និងយន្តការដឹកនាំតាមការចាំបាច់ សម្រាប់គ្រប់គ្រង និងចាត់ចែងការអនុវត្តកម្មវិធីឱ្យមានប្រសិទ្ធភាព
- សហការរៀបចំគម្រោងថវិកាប្រចាំឆ្នាំសម្រាប់ដំណើរការកម្មវិធីនៅថ្នាក់ក្រោមជាតិ
- ពិនិត្យ និងតាមដានការផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងអំពីកម្មវិធីដល់គ្រួសារគោលដៅនៅតាមទីតាំងភូមិសាស្ត្រគោលដៅ និងជូនដល់ភាគីពាក់ព័ន្ធ
- ផ្តល់ទិន្នន័យគ្រួសារមានបណ្ណសមធម៌ដែលបានជ្រើសរើស មកក្រសួងផែនការ និងមូលនិធិជាតិជំនួយសង្គម
- រៀបចំឧបករណ៍ និងកម្មវិធីបណ្តុះបណ្តាល និងបង្វឹកជូនគ្រួសារទទួលផល ដោយសហការជាមួយភាគីពាក់ព័ន្ធ
- តាមដានដំណើរការផ្តល់វគ្គបណ្តុះបណ្តាល និងការបង្វឹក ដែលអនុវត្តដោយរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- តាមដានដំណើរការពិនិត្យ និងជំរុញការប្រើប្រាស់ប្រាក់ដើមទុនសម្រាប់ទ្រព្យសកម្មរបស់គ្រួសារទទួលផល ដែលអនុវត្តដោយរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីធានាឱ្យបានការប្រើប្រាស់ប្រាក់ដើមទុនចំគោលដៅ
- តាមដានដំណើរការចុះសួរសុខទុក្ខ និងបង្វឹកតាមខ្នងផ្ទះ ដែលអនុវត្តដោយរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- សម្របសម្រួល និងផ្តល់សេវាតភ្ជាប់ទៅកាន់កម្មវិធី និងរបបក្នុងប្រព័ន្ធគាំពារសង្គម និងសេវាបំពេញបន្ថែមនានា ព្រមទាំងឱកាសទីផ្សារ
- ពិនិត្យ និងតាមដានការអនុវត្តកម្មវិធី ព្រមទាំងដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីនៅរដ្ឋបាលរាជធានី ខេត្តសាមី និង
- រៀបចំរបាយការណ៍ជាប្រចាំជូន អ.ក.គ. ម.ជ.ជ. និងភាគីពាក់ព័ន្ធ អំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តកម្មវិធី។

**មាត្រា២៣.-**

រដ្ឋបាលក្រុង ស្រុក ខណ្ឌគោលដៅ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ដឹកនាំ និងគ្រប់គ្រងការអនុវត្តកម្មវិធីក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងអំពីកម្មវិធីជូនគ្រួសារដែលមានបណ្ណសមធម៌
- កៀរគរ និងចុះឈ្មោះគ្រួសារដែលមានបណ្ណសមធម៌ចូលរួមក្នុងកម្មវិធី
- ផ្តល់ការបណ្តុះបណ្តាល និងការបង្វឹកដល់គ្រួសារទទួលផល ដោយសម្របសម្រួល និងមានការគាំទ្រពីមន្ត្រីបច្ចេកទេសកសិកម្ម និងភាគីពាក់ព័ន្ធ
- រៀបចំយន្តការគ្រប់គ្រង និងចាត់ចែងការចុះបង្វឹកតាមខ្នងផ្ទះ
- តាមដាន និងជំរុញការប្រើប្រាស់ប្រាក់ដើមទុនសម្រាប់ទ្រព្យសកម្មរបស់គ្រួសារទទួលផល ដើម្បីធានាឱ្យបានការប្រើប្រាស់ចំគោលដៅ និង
- ពិនិត្យ និងតាមដានការអនុវត្តកម្មវិធី ព្រមទាំងដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និង
- រៀបចំរបាយការណ៍ជាប្រចាំជូនរដ្ឋបាលរាជធានី ខេត្តរបស់ខ្លួន អំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តកម្មវិធី។

**មាត្រា២៤.-**

រដ្ឋបាលឃុំ សង្កាត់គោលដៅ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- គាំទ្រដំណើរការផ្សព្វផ្សាយ បញ្ជ្រាបការយល់ដឹង កៀរគរ និងចុះឈ្មោះគ្រួសារមានបណ្ណសមធម៌ក្នុងកម្មវិធី
- គាំទ្រដំណើរការផ្តល់ការបណ្តុះបណ្តាល និងការបង្វឹកជូនគ្រួសារទទួលផល
- គាំទ្រដំណើរការចុះសួរសុខទុក្ខ និងបង្វឹកតាមខ្នងផ្ទះ ព្រមទាំងតាមដានវឌ្ឍនភាពគ្រួសារទទួលផលនៃកម្មវិធី
- ចូលរួមកម្មវិធីពង្រឹងសមត្ថភាពសម្រាប់អនុវត្តកម្មវិធីដែលផ្តល់ដោយរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ចូលរួមពិនិត្យ និងតាមដានការអនុវត្តកម្មវិធី ព្រមទាំងដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និង
- រៀបចំរបាយការណ៍ជាប្រចាំជូនរដ្ឋបាលក្រុង ស្រុក ខណ្ឌ របស់ខ្លួន អំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តកម្មវិធី។

## ជំពូកទី៥
## ថវិកាអនុវត្តកម្មវិធី

**មាត្រា២៥.-**

រាល់ចំណាយលើការអនុវត្តកម្មវិធី ត្រូវផ្តល់ហិរញ្ញប្បទានដោយថវិកាជាតិ តាមរយៈមូលនិធិហិរញ្ញប្បទានគាំពារសង្គម (ម.គ.ស.) និងថវិកាពីប្រភពស្របច្បាប់ផ្សេងទៀត។

ថវិកាសម្រាប់ការអនុវត្តកម្មវិធីនេះ ត្រូវគ្រោងនៅក្នុងកញ្ចប់ថវិការបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ព្រមទាំងគ្រោងចំណូល ចំណាយទៅតាមមាតិកានៅក្នុងក្របខណ្ឌនៃកញ្ចប់ថវិការបស់មូលនិធិជាតិជំនួយសង្គម (ម.ជ.ជ.) ដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។



៥

**មាត្រា២៦ .-**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវបោះផ្សាយអាណត្តិបើកប្រាក់ឧបត្ថម្ភធនសម្រាប់ការអនុវត្តកម្មវិធីនេះមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីផ្ទេរថវិកានេះ នៅរៀងរាល់ត្រីមាស ឬតាមតម្រូវការចំណាយជាក់ស្តែង រក្សាទុកក្នុងគណនីប្រាក់បញ្ញើរបស់ ម.គ.ស. នៅធនាគារជាតិ ឬធនាគារជាតិនៃកម្ពុជា អនុលោមតាមអនុក្រឹត្យលេខ ២២៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការបង្កើតមូលនិធិហិរញ្ញប្បទានគាំពារសង្គម។

ថវិកាឧបត្ថម្ភធននេះជាចំណាយរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលជាអាណាព្យាបាលបច្ចេកទេស។

ម.ជ.ជ. និងរដ្ឋបាលរាជធានី ខេត្តគោលដៅ ត្រូវរៀបចំស្នើសុំបើកប្រាក់ប្រចាំត្រីមាស ឬតាមតម្រូវការចំណាយជាក់ស្តែង ដោយភ្ជាប់មកជាមួយនូវគ្រោងចំណាយលម្អិត តាមរយៈ អ.ក.គ. ដើម្បីលើកការស្នើសុំបើកប្រាក់ជូនប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម ពិនិត្យ និងសម្រេច។

អ.ក.គ. រៀបចំផ្តល់សាច់ប្រាក់ជូន ម.ជ.ជ. និងរដ្ឋបាលរាជធានី ខេត្តគោលដៅ តាមរយៈមូលប្បទានបត្រ ឬការផ្ទេរសាច់ប្រាក់ចូលគណនីរបស់ ម.ជ.ជ. និងរដ្ឋបាលរាជធានី ខេត្តគោលដៅ បន្ទាប់ពីទទួលបានការពិនិត្យ និងសម្រេចរបស់ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម ផ្តល់ថវិកាតាមការស្នើសុំ។

**មាត្រា២៧ .-**

ម.ជ.ជ. និងរដ្ឋបាលរាជធានី ខេត្តគោលដៅ ត្រូវប្រមូលលិខិតយុត្តការចំណាយដើម្បីជម្រះចំណាយជាប្រចាំជាមួយ ម.គ.ស. ដែលមាន អ.ក.គ. ជាសេនាធិការ និងធ្វើរបាយការណ៍បិទបញ្ជីចំណូលចំណាយប្រចាំឆ្នាំ ស្របតាមបទដ្ឋានគតិយុត្តហិរញ្ញវត្ថុជាធរមាន។

## ជំពូកទី៦
## របាយការណ៍ និងការចុះពិនិត្យការអនុវត្តកម្មវិធី

**មាត្រា២៨ .-**

ម.ជ.ជ. និងរដ្ឋបាលរាជធានី ខេត្តគោលដៅ ត្រូវផ្តល់របាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំអំពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីជូនក្រុមប្រឹក្សាជាតិគាំពារសង្គម និងចម្លងជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

របាយការណ៍ប្រចាំត្រីមាសត្រូវផ្តល់យ៉ាងយូរក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីដំណាច់ត្រីមាសនីមួយៗ។

របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់យ៉ាងយូរក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីដំណាច់ឆ្នាំនីមួយៗ។

ក្នុងករណីចាំបាច់ ម.ជ.ជ. និងរដ្ឋបាលរាជធានី ខេត្តគោលដៅ ត្រូវផ្តល់របាយការណ៍ពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី តាមការស្នើសុំរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម។

**មាត្រា២៩ .-**

ម.ជ.ជ. និងរដ្ឋបាលរាជធានី ខេត្តគោលដៅ ត្រូវរៀបចំរបាយការណ៍ចំណូល និងចំណាយថវិកាប្រចាំខែ និងប្រចាំឆ្នាំ ស្តីពីការអនុវត្តកម្មវិធី ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន និងត្រូវចម្លងជូនក្រុមប្រឹក្សាជាតិគាំពារសង្គម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ការអនុវត្តកម្មវិធីនេះ ត្រូវស្ថិតនៅក្រោមអធិការកិច្ច និងសវនកម្មអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

**មាត្រា៣០.-**

ក្រុមប្រឹក្សាជាតិគាំពារសង្គម មានសិទ្ធិចាត់តាំងមន្ត្រីជំនាញនៃ អ.ក.គ. ចុះពិនិត្យ និងសង្កេតជាក់ស្តែងដល់ទីកន្លែង អំពីប្រសិទ្ធភាពនៃការអនុវត្តកម្មវិធី។

## ជំពូកទី៧
## ការដោះស្រាយវិវាទ ឬបណ្តឹង

**មាត្រា៣១.-**

វិវាទ ឬបណ្តឹងដែលពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីជាតិគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្រ ត្រូវដោះស្រាយក្នុងកម្រិត ម.ជ.ជ. និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាប្រតិបត្តិករ។ រាល់វិវាទ ឬបណ្តឹង ដែលមិនអាចដោះស្រាយបានតាមយន្តការសម្របសម្រួលក្នុងកម្រិតប្រតិបត្តិករ ភាគីណាមួយនៃវិវាទ ឬបណ្តឹង អាចប្តឹងបន្តទៅអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គមដើម្បីសម្របសម្រួលដោះស្រាយ។

## ជំពូកទី៨
## ទណ្ឌកម្ម

**មាត្រា៣២.-**

បុគ្គលពាក់ព័ន្ធដែលប្រព្រឹត្តផ្ទុយនឹងបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ឬត្រូវបានរកឃើញថា មានការប្រព្រឹត្តមិនប្រក្រតី នៅក្នុងដំណើរការនៃការអនុវត្តកម្មវិធី ត្រូវទទួលទណ្ឌកម្ម ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៩
## ករណីប្រធានសក្តិ

**មាត្រា៣៣.-**

ក្នុងករណីប្រធានសក្តិ ឬមានវិបត្តិធ្ងន់ធ្ងរកើតឡើង ដែលបណ្តាលឱ្យប៉ះពាល់ដល់ដំណើរការកម្មវិធី មូលនិធិជាតិជំនួយសង្គម និងរដ្ឋបាលរាជធានី ខេត្តគោលដៅ ត្រូវស្នើសុំក្រុមប្រឹក្សាជាតិគាំពារសង្គមដោយលើកជាជម្រើសដំណោះស្រាយសមស្រប ដើម្បីឱ្យអ្នកទទួលផលទទួលបានអត្ថប្រយោជន៍ក្រោមកម្មវិធី ដូចមានកំណត់ក្នុងគោលការណ៍ណែនាំស្តីពីការអនុវត្តកម្មវិធីជាតិគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្រ។

## ជំពូកទី១០
## រយៈពេលនៃការអនុវត្ត

**មាត្រា៣៤.-**

កាលបរិច្ឆេទ និងរយៈពេល នៃការអនុវត្តកម្មវិធីជាតិគាំពារសង្គមដើម្បីជំរុញការចាកចេញពីភាពក្រីក្រ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម។



9

## ជំពូកទី១១
## អវសានប្បញ្ញត្តិ

**មាត្រា៣៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រីគ្រប់ក្រសួង អគ្គនាយកនៃមូលនិធិជាតិជំនួយសង្គម ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់កម្រិត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៦រោច ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែសីហា ឆ្នាំ២០២៥
**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សូមហត្ថលេខា
**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ